# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃអង្គារ ៨កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃសុក្រ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣២រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៧រូប សរុបចំនួន៦៩រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ ពិនិត្យ និងពិភាក្សាលើការជំរុញអនុវត្ត «សារាចរលេខ២០សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយ ដើម្បីបង្ការមេរោគអេដស៍ និងជំងឺអេដស៍របស់រាជរដ្ឋាភិបាល»។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

នៅព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦នេះ ខ្ញុំបាទបានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៦ ដើម្បីពិនិត្យ និងពិភាក្សាលើការជំរុញការអនុវត្ត «សារាចរលេខ២០សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យ ឱ្យបាន១០០ភាគរយ ដើម្បីបង្ការមេរោគអេដស៍និងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល»។

ជាបឋម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារ ក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក។ ការសម្រេចបាននូវលទ្ធផលល្អប្រសើរកន្លងមកនេះ ដោយសារមានការយកចិត្តទុកដាក់គិតគូប្រកបដោយគតិបណ្ឌិតរបស់**សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដោយមានចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការឈានទៅសម្រេចបានគោលនយោបាយជាតិទាំងបីនៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ។

២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ។

៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

ឯកឧត្តមក៏បានជម្រាបជូនអង្គប្រជុំ មេរោគអេដស៍នៅតែបន្តឆ្លង ជាពិសេសក្នុងចំណោមប្រជាជនប្រឈមមុខខ្ពស់ និងដៃគូ។ តាមទិន្នន័យឆ្នាំ២០២៤ ការឆ្លងថ្មីនៃមេរោគអេដស៍មាន១២០០នាក់ ដែលក្នុងនោះប្រជាជនប្រឈមមុខខ្ពស់មានប្រមាណ៨០% ជាពិសេសក្នុងចំណោមយុវវ័យដែលមានអាយុចន្លោះពី១៥ឆ្នាំ ទៅ២៤ឆ្នាំមាន៤៤%។ ក្នុងគោលបំណងបញ្ចប់ការឆ្លងថ្មី រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ២០សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពី ការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន ១០០ភាគរយ។ បន្ទាប់ពីកិច្ចពិភាក្សាយ៉ាងផុសផុលរួចមក ឯកឧត្តមបានផ្តល់អនុសាសន៍ដល់សមាជិកនៃកិច្ចប្រជុំឱ្យជំរុញការផ្សព្វផ្សាយ ដល់សាធារណៈជន ជាពិសេសយុវវ័យឱ្យយល់ថាអេស៍គឺមិនទាន់អស់ទេ នៅតែបន្តឆ្លងជារៀងរាល់ថ្ងៃ និងសូមឱ្យបង្ការខ្លួនកុំឱ្យឆ្លងមេរោគអេដស៍ និងសូមឱ្យក្រសួង ស្ថាប័ន ខេត្ត ក្រុង ជំរុញការផ្សព្វផ្សាយសារាចរលេខ២០សរ ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០ភាគរយ ដើម្បីបង្ការមេរោគអេដស៍ និងជំងឺអេដស៍របស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៣-២០២៨ ដែលមានចក្ខុវិស័យៈ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ រើសអើង និងមានបេសកកម្ម ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្នដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន និងមានចីរភាព ដោយមានគោលដៅ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាពដែលធានាថា ជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១:៣០នាទី ថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**

បានពិនិត្យត្រឹមត្រូវ

ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

**វេជ្ជ. ហួត សេរីវុឌ្ឍ**

បានឃើញ និងឯកភាព

ប្រធានអង្គប្រជុំ

**បណ្ឌិត ឈឹម យិនដារ៉េត**